# សេចក្ដីប្រកាសទទួលយកសំណើគម្រោងសុំមូលនិធិ
# នៅតំបន់ហតស្ពត ឥណ្ឌូ-ភូមា

**កាលបរិច្ឆេទចាប់ផ្ដើមទទួល៖** ១៥ សីហា ឆ្នាំ២០២២
**កាលបរិច្ឆេទឈប់ទទួល៖** ២៦ កញ្ញា ឆ្នាំ២០២២
**ទំហំមូលនិធិ៖** ខ្នាតតូច (ត្រឹម៤០.០០០ដុល្លារសហរដ្ឋអាមេរិក) និងខ្នាតធំ(ចាប់ពី៤០.០០០ដុល្លារសហរដ្ឋអាមេរិក ដល់២០០.០០០ដុល្លារសហរដ្ឋអាមេរិក)
**ប្រទេសដែលមានសិទ្ធិដាក់៖** កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃឡង់ដ៍ និងវៀតណាម
**អាទិភាព៖** ផ្ដោតលើទិសដៅយុទ្ធសាស្រ្តទី៤ និងទី៦
**ភាសា:** លេខាធិការដ្ឋានមូលនិធិ CEPF ទទួលសំណើគម្រោងសុំមូលនិធិខ្នាតធំជាភាសាអង់គ្លេស បារាំង ព័រទុយហ្គាល់ និងអេស្ប៉ាញ។ អង្គការ IUCN ទទួលសំណើគម្រោងសុំមូលនិធិខ្នាតតូច ជាភាសាខ្មែរ ចិន អង់គ្លេស ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។

មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគម្រាមកំហែង (CEPF) និងអង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) សូមប្រកាសចាប់ផ្ដើមទទួលយកសំណើគម្រោងសុំមូលនិធិពីបណ្ដាអង្គការមិនមែនរដ្ឋាភិបាល ក្រុមសហគមន៍ អង្គការរបស់ជនជាតិដើមភាគតិច ក្រុមស្ត្រី ក្រុមហ៊ុនឯកជន និងអង្គការសង្គមស៊ីវិលផ្សេងៗទៀត សម្រាប់គម្រោងទាំងឡាយណា ដែលដោះស្រាយនូវបញ្ហានៃការអភិរក្សជីវចម្រុះនៅតំបន់ហតស្ពតឥណ្ឌូ-ភូមា និងដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យដែលបានចែងក្នុងសេចក្ដីប្រកាសនេះ។

មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគម្រាមកំហែង(CEPF) ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីការពារតំបន់ដែលរងការគម្រាមកំហែង និងសំបូរទៅដោយធនធានជីវចម្រុះច្រើនបំផុតនៅលើភពផែនដី ដែលស្គាល់ថាជាតំបន់ហតស្ពតជីវចម្រុះ(Biodiversity Hotspots)។ មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគម្រាមកំហែងនេះ ជាកិច្ចផ្ដួចផ្ដើមរួមមួយរវាងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង អង្គការអភិរក្សអន្តរជាតិ សហភាពអឺរ៉ុប មូលនិធិបរិស្ថានពិភពលោក រដ្ឋាភិបាលជប៉ុន និងធនាគារពិភពលោក។ នៅតំបន់ហតស្ពតជីវចម្រុះឥណ្ឌូ-ភូមា មូលនិធិ CEPF ក៏ត្រូវបានគាំទ្រដោយ មូលនិធិម៉ាហ្គារ៉ែតអា.កាហ្គើលផងដែរ។ គោលបំណងសំខាន់គឺដើម្បីធានាឲ្យមានការចូលរួមពីអង្គការសង្គមស៊ីវិលក្នុងការអភិរក្សជីវចម្រុះ។

តំបន់ហតស្ពតឥណ្ឌូ-ភូមា រួមមាន តំបន់ទាំងអស់ ដោយមិនរាប់បញ្ចូលនូវតំបន់សមុទ្រនៃប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃនិងវៀតណាម ព្រមទាំងផ្នែកខ្លះនៃភាគខាងត្បូងប្រទេសចិន។
ការប្រកាសទទួលយកសំណើគម្រោងសុំមូលនិធិលើកនេះ គឺទទួលយកសំណើគម្រោងទាំងឡាយណាដែលដោះស្រាយអាទិភាពនៃការវិនិយោគមួយឬពីរដូចខាងក្រោមនេះ។ ការប្រកាសទទួលយកសំណើគម្រោងសុំមូលនិធិនាពេលខាងមុខទៀត នឹងប្រកាសនៅលើវេបសាយ CEPF និងព្រឹត្តិបត្រព័ត៌មានតាមអ៊ីនធឺណែត បើសិនជាមាន។

មូលនិធិនឹងផ្ដល់ជូនចំពោះគម្រោង ដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យ៖ (i)មានលក្ខណៈសង្គតិភាពល្អបំផុតទៅនឹងអាទិភាពវិនិយោគ ដែលបានបញ្ជាក់ក្នុងសេចក្ដីប្រកាសនេះ។(ii) មានលទ្ធភាពខ្ពស់ក្នុងការសម្រេចបាននូវទិសដៅដែលបានកំណត់ និងរួមចំណែកជាសារវន្តដល់លទ្ធផលអភិរក្សប្រកបដោយនិរន្តរភាព។ (iii) បំពេញបន្ថែមលើគំនិតផ្ដួចផ្ដើមកន្លងមកនិងគំនិតផ្ដួចផ្ដើមដែលមានជាបន្តបន្ទាប់; (iv) ជាគម្រោងដែលមានគុណតម្លៃខ្ពស់ និង(v) បង្ហាញពីសមត្ថភាពស្ថាប័ន និងបទពិសោធន៍ចាំបាច់ ក្នុងការអនុវត្តគម្រោងនេះ។ មូលនិធិ CEPF សូមស្វាគមន៍ចំពោះសំណើគម្រោងសុំមូលនិធិពីបណ្ដាអង្គការដៃគូទទួលមូលនិធិ បច្ចុប្បន្ននិងអតីតកាល ក៏ដូចជាអង្គការដែលមិនធ្លាប់ទទួលបានមូលនិធិពី CEPF ពីមុន។ ទោះយ៉ាងណា សម្រាប់គម្រោងនៅប្រទេសមីយ៉ាន់ម៉ា មានតែដៃគូទទួលមូលនិធិរបស់ CEPF ពីមុនទេ ទើបមានសិទ្ធិគ្រប់គ្រាន់ក្នុងការលើកសំណើទៀត។

អ្នកដាក់សំណើគម្រោងសុំមូលនិធិទាំងឡាយ ត្រូវបានលើកទឹកចិត្តឲ្យស្វែងយល់បន្ថែម ពី Ecosystem Profile_សម្រាប់តំបន់ឥណ្ឌូ-ភូមា និងទាក់ទងក្រុមការងារគ្រប់គ្រងមូលនិធិ CEPF ប្រចាំនៅ

តំបន់ហតស្តតគណ្ឌូ-ភូមា នៃអង្គការ IUCN តាមរយៈ(អ៊ីម៉ែល: CEPF-Indoburma@iucn.org) ប្រសិនបើអ្នកមានសំណួរឬ ចង់ពិភាក្សាអំពីគំនិតនានាដែលអ្នកចង់លើកឡើងក្នុងគម្រោងរបស់អ្នក។ អ្នកដាក់សំណើគម្រោងសុំមូលនិធិ ត្រូវបានលើកទឹកចិត្តឲ្យចូលមើលបន្ថែមលើគេហទំព័រ CEPF ជាពិសេសផ្នែកស្តីពី លក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានសិទ្ធិក្នុងការដាក់ពាក្យស្នើសុំមូលនិធិ មុនពេលអ្នកដាក់ពាក្យ និងរបៀបដាក់ពាក្យ។

## អាទិភាពដែលនឹងផ្តល់បានមូលនិធិក្នុងសេចក្តីប្រកាសលើកនេះ

**ទិសដៅយុទ្ធសាស្ត្រទី៤៖ ផ្តល់សិទ្ធិអំណាចដល់សហគមន៍មូលដ្ឋានក្នុងការចូលរួមអភិរក្ស និងគ្រប់គ្រងតំបន់ជីវចម្រុះសំខាន់ៗអាទិភាព**

***សូមកត់សម្គាល់ថា៖*** *លើកលែងតែអាទិភាពវិនិយោគទី ៤.៤ ដែលផ្តោតលើការកំណត់អត្តសញ្ញាណកម្មតំបន់ជីវចម្រុះសំខាន់ៗ ដើម្បីមានសិទ្ធិទទួលបានការគាំទ្រមូលនិធិក្រោមទិសដៅយុទ្ធសាស្ត្រនេះ គម្រោងត្រូវផ្តោតលើទីតាំងអាទិភាពមួយឬច្រើន ដូចដែលមានកំណត់ក្នុងតារាង ២៧ នៅក្នុងឯកសារស្តីពីលក្ខណៈប្រព័ន្ធអេកូឡូស៊ី។ ដោយទទួលស្គាល់តួនាទីសំខាន់ នៃទំនាក់ទំនងយេនឌ័រក្នុងការប្រើប្រាស់ និងការចូលរួមរបស់បុរសនិងស្ត្រីក្នុងការគ្រប់គ្រងធនធានធម្មជាតិ គម្រោងត្រូវបញ្ចូលការពិចារណាយេនឌ័រទៅក្នុងការគាក់តែងគម្រោងនិងការអនុវត្តគម្រោង។*

មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែង(CEPF) និង អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) សូមប្រកាសទទួលយកសំណើគម្រោងសុំមូលនិធិ ដែលដោះស្រាយអាទិភាពវិនិយោគមួយ ឬច្រើន ដូចខាងក្រោម៖

**៤.២** សាកល្បង ពង្រីក និងអភិវឌ្ឍយន្តការនិរន្តរភាពសម្រាប់សហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ តាមរយៈដំណើរការដែលដឹកនាំដោយសហគមន៍។

**៤.៣** បង្កើតយន្តការគ្រប់គ្រងរួមសម្រាប់តំបន់ការពារ ដែលអាចឱ្យសហគមន៍ចូលរួមក្នុងការកំណត់តំបន់ ការគ្រប់គ្រង និងអភិបាលកិច្ច។

**៤.៤** ពិនិត្យឡើងវិញនូវអត្តសញ្ញាណតំបន់ជីវចម្រុះសំខាន់ៗនៅក្នុងតំបន់ហតស្តត ដោយប្រើ ស្តង់ដារ KBA ថ្មី

**ទិសដៅយុទ្ធសាស្ត្រទី៦៖ បង្ហាញពីអភិក្រមក្នុងការបញ្ជ្រាបសេវាកម្មជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ីទៅក្នុងផែនការអភិវឌ្ឍ ក្នុងតំបន់របៀងជីវចម្រុះអាទិភាពនានា**

***សូមកត់សម្គាល់ថា៖*** *ដើម្បីមានសិទ្ធិទទួលបានការគាំទ្រមូលនិធិ ក្រោមទិសដៅយុទ្ធសាស្ត្រនេះ គម្រោងត្រូវតែ៖ (i) បង្ហាញពី អភិក្រម ដែលអាចយកទៅអនុវត្តតាមបាន ដោយអង្គការសង្គមស៊ីវិលឬវិស័យឯកជនឬយកទៅដាក់បញ្ចូលទៅក្នុងកម្មវិធីនានា របស់រដ្ឋាភិបាល និង(ii) ផ្តោតលើរបៀងជីវចម្រុះមួយក្នុងចំណោមរបៀងជីវចម្រុះទាំង៥ ដែលមានក្នុងតារាងទី២៧ ក្នុងឯកសារស្តីពីលក្ខណៈប្រព័ន្ធអេកូឡូស៊ី ឬតំបន់ជីវចម្រុះសំខាន់ៗនៃតំបន់ថ្មកំបោរមួយក្នុងចំណោមតំបន់ថ្មកំបោរទាំង២៤កន្លែងនៃប្រទេសមីយ៉ាន់ម៉ា។*

មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែង(CEPF) និង អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) សូមប្រកាសទទួលយកសំណើគម្រោងសុំមូលនិធិ ដែលដោះស្រាយអាទិភាពវិនិយោគមួយ ឬច្រើន ដូចខាងក្រោម៖

**៦.១** វិភាគលើគោលនយោបាយអភិវឌ្ឍ ផែនការ និងកម្មវិធីនានា វាយតម្លៃពីប៉ះពាល់នៃគោលនយោបាយ ផែនការ និងកម្មវិធីទាំងនោះលើសេវាកម្មជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ី និងស្នើលើកឡើង និងគាំទ្រឲ្យមានការអនុវត្តនូវសេណារីយ៉ូការអភិវឌ្ឍជាជម្រើស ដំណោះស្រាយផ្អែកលើធម្មជាតិ និងវិធានកាត់បន្ថយនូវផលប៉ះពាល់ ជាដើម។

**៦.២ រៀបចំគម្រោងបង្ហាញ**សម្រាប់ការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី ដោយមានការបង្កើតជាពិធីសារស្តារប្រព័ន្ធអេកូឡូស៊ីសមស្របដែលអាចយកអនុវត្តតាមបាន

**៦.៣** បញ្ចូលប្រព័ន្ធឃោសនាព័ត៌មានជាវិធីសាស្ត្រមួយដើម្បីបង្កើនការយល់ដឹង និងជូនដំណឹងពីការជជែកដេញដោលជាសាធារណៈ និងមានឥទ្ធិពលលើការសម្រេចចិត្តក្នុងការបញ្ជ្រាបជីវចម្រុះទៅក្នុងការរៀបចំផែនការអភិវឌ្ឍ

**៦.៤** សាកល្បង និងពង្រីកការអនុវត្តតាមគំរូនានាសម្រាប់ផលិតកម្មមេត្រីភាពជីវចម្រុះ រួមមានការបញ្ជាក់ដោយវិញ្ញាបនបត្រ និងការបង្កើតជានិមិត្តសញ្ញា (ស្លាកយីហោ) សម្គាល់ផលិតផលធម្មជាតិ។

## ព័ត៌មានបន្ថែម

សេចក្តីប្រកាសនេះ គឺបើកចំហចំពោះបណ្តាអង្គការជាតិ និងអន្តរជាតិ ក្នុងតំបន់ហតស្តតគណ្ឌូ-

ភូមា។ រាល់បុគ្គល ដែលមានបំណងដាក់សំណើសុំមូលនិធិ ត្រូវធ្វើការជាមួយអង្គការសង្គមស៊ីវិល ដើម្បីសរសេរសំណើគម្រោងសុំមូលនិធិនេះ ជាជាងការដាក់ស្នើសុំជាលក្ខណៈបុគ្គល។ សូមកត់សម្គាល់ថាមូលនិធិនឹងត្រូវផ្តល់ទៅឲ្យគម្រោងដែលបង្ហាញពីតួនាទីឈានមុខគេ សម្រាប់អង្គការក្នុងស្រុកនានានិង/ឬការផ្តោតសង្កត់ធ្ងន់ជាក់លាក់លើការកសាងសមត្ថភាពសម្រាប់សង្គមស៊ីវិលមូលដ្ឋាន។ ក៏នឹងមានការផ្តល់ជូនផងដែរដល់គម្រោងទាំងឡាយណាដែល បានគិតគូរពីបញ្ហាយេនឌ័រស្របតាមគោលនយោបាយយេនឌ័រនិងឧបករណ៍ណែនាំស្តីពីយេនឌ័រនៃមូលនិធិ CEPF។ សូមមើលឯកសារខ្លីស្តីពីយេនឌ័ររបស់ CEPF។

មូលនិធិដែលផ្តល់ឲ្យមិនអាចយកទៅប្រើប្រាស់សម្រាប់៖ (១) ទិញដី (២) សកម្មភាពរុះរើ ឬធ្វើឲ្យខូចដល់ទ្រព្យសម្បត្តិវប្បធម៌រូបវន្ត (ដូចជា ទីតាំងដែលមានតម្លៃផ្នែកបុរាណវត្ថុវិទ្យា ផ្នែកបាសាណិភូតវិទ្យា ផ្នែកប្រវត្តិសាស្ត្រ សាសនា ឬក៏តម្លៃរបស់ធម្មជាតិដែលមានតែមួយ (៣) ផ្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ឬក៏ការ រុះរើតាំងទីលំនៅសារជាថ្មីដោយគ្មានការស្ម័គ្រចិត្ត (៤) យកទៅផ្គត់ផ្គង់បន្ថែមទៅលើមូលនិធិអាណាព្យាបាលភាព (ត្រាស់ហ្វាន់)។ រាល់សកម្មភាព ទាំងអស់ត្រូវគោរពតាមគោលនយោបាយការពារសុវត្ថិភាពសង្គមនិងបរិស្ថានរបស់មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគម្រាមកំហែង ដែលអាចរកបាន សូមចុចត្រង់នេះ។

## របៀបដាក់សំណើគម្រោង

**អ្នកលើកសំណើគម្រោងសុំមូលនិធិខ្នាតតូច (ត្រឹម ៤០.000ដុល្លារសហរដ្ឋអាមេរិក)** អាចដាក់ជាភាសាខ្មែរ អង់គ្លេស ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ដោយប្រើគំរូសំណើគម្រោងដែលមាន សូមចុចត្រង់នេះ។ គម្រោងដែលបានលើកឡើងគួរមានរយៈពេលពីចាប់ពី ៦ខែ-២៤ខែ ជាមួយនឹងការគ្រោងចាប់ផ្តើមអនុវត្តគម្រោងចាប់ពីថ្ងៃទី ០១ មីនា ឆ្នាំ២០២៣។ នៅពេលសំណើត្រូវបានរៀបចំរួច សូមផ្ញើអ៊ីម៉ែលមកកាន់ CEPF-Indoburma@iucn.org។សូមដាក់ឈ្មោះសំណើសុំមូលនិធិរបស់ស្ថាប័នរបស់អ្នកក្នុងទម្រង់ដូចនេះ៖ **អក្សរកាត់អង្គការរបស់អ្នក**_CEPF SG Letter of Inquiry។ ជាឧទាហរណ៍៖ IUCN_CEPF SG Letter of Inquiry។ ការទទួលបាននូវសំណើគម្រោងរបស់អ្នកនឹងត្រូវជម្រាបជូនតាមរយៈអ៊ីម៉ែល។ លោកលោកស្រីនឹងត្រូវបានទាក់ទងពីជំហាន ដែលនឹងត្រូវធ្វើបន្ទាប់ទៀត។ រាល់សំណួរ ឬចម្ងល់ក្នុងអំឡុងពេលនៃដំណើរការលើកសំណើសុំនេះ អាចសាកសួរបានតាមរយៈអ៊ីម៉ែល៖ CEPF-Indoburma@iucn.org ។

រាល់សំណើគម្រោងទាំងអស់នឹងត្រូវពិនិត្យវាយតម្លៃដើម្បីបញ្ជាក់ពីលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមុនសិន។ រាល់សំណើគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ហើយ នឹងត្រូវពិនិត្យមើលឡើងវិញជា បឋមតាមលក្ខណៈវិនិច្ឆ័យដូចបានរៀបរាប់ខាងលើ។ បន្ទាប់មក សំណើគម្រោងដែលបានជាប់សំរាំង នឹងយកទៅពិនិត្យមើល និងវាយតម្លៃថែមទៀតនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការវាយតម្លៃសំណើគម្រោងថ្នាក់ជាតិ។ ការសម្រេចដែលនឹងផ្តល់មូលនិធិដល់សំណើគម្រោងណានោះ គឺពិនិត្យមើលទៅលើអនុសាសន៍ពីកិច្ចប្រជុំគណៈកម្មាធិការវាយតម្លៃសំណើគម្រោងថ្នាក់ជាតិនេះ។

**អ្នកដាក់សំណើគម្រោងសុំមូលនិធិខ្នាតធំ (លើសពី៤០.000 ដល់ ២០០.000ដុល្លារសហរដ្ឋអាមេរិក)** ត្រូវដាក់តាមអនឡាញ ConservationGrants។ សម្រាប់លោកអ្នកដែលដាក់សំណើគម្រោងជាលើកដំបូង ត្រូវចុះឈ្មោះជាមុនសិនដើម្បីបង្កើតគណនេយ្យ។ រាល់អ្នកដាក់សំណើណា ដែលជួបប្រទះបញ្ហាបច្ចេកទេសជាមួយនឹងកម្មវិធីផតថលតាមអនឡាញ សូមទាក់ទងមក៖ conservationgrants@conservation.org។

ជំហានដំបូងនៃដំណើរការដាក់ពាក្យសុំមូលនិធិ គឺត្រូវដាក់ឯកសារគោលគំនិតខ្លីនៃគម្រោងតាមអនឡាញជាមុនសិន។ ឯកសារគោលគំនិតខ្លីនៃគម្រោង អាចដាក់បាន ជាភាសាអង់គ្លេស បារាំង ព័រទុយហ្គាល់ឬអេស្ប៉ាញ។ អ្នកស្នើសុំ ត្រូវបានណែនាំឱ្យរៀបចំឯកសារគោលគំនិតខ្លីនៃគម្រោង ដែលមានរយៈពេលចាប់ពី ១២-៣០ខែ ជាមួយនឹងកាលបរិច្ឆេទចាប់ផ្តើមប៉ាន់ស្មានថ្ងៃទី ០១ ខែមីនា ឆ្នាំ២០២៣។ ឯកសារគោលគំនិតខ្លីនៃគម្រោង ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងត្រូវឆ្លងកាត់ការពិនិត្យបច្ចេកទេសដោយលេខាធិការដ្ឋាន CEPF និងអង្គការ IUCN ដោយប្រើលក្ខណៈវិនិច្ឆ័យដែលបានរៀបរាប់ខាងលើ។ អ្នកដាក់សំណើគម្រោងសុំមូលនិធិដែលជាប់នៅដំណាក់កាលដំបូង នឹងត្រូវបានអញ្ជើញឲ្យធ្វើបទបង្ហាញពីគម្រោងរបស់ពួកគេទៅកាន់គណៈកម្មាធិការវាយតម្លៃសំណើគម្រោង ហើយពួកគេនឹងត្រូវបានជូនដំណឹងថាតើពួកគេត្រូវបានអញ្ជើញមកកាន់ដំណាក់កាលសំណើគម្រោងពេញលេញឬអត់។

សេចក្តីណែនាំលម្អិតស្តីពីការសរសេរសំណើគម្រោងពេញលេញនឹងផ្តល់ជូនដល់ដៃគូលើកសំណើគម្រោងដែលបានជាប់នៅដំណាក់កាលទី១ ជាមួយនឹងលិខិតជូនដំណឹងជាផ្លូវការ។ ដៃគូលើកសំណើគម្រោងនឹងត្រូវផ្តល់រយៈពេល ៦សប្តាហ៍ក្នុងការរៀបចំសំណើគម្រោងពេញលេញតាមរយៈកម្មវិធីវិបសាយ (ផតថល)។ ក្នុងអំឡុងពេលនោះ អ្នកដាក់សំណើគម្រោងដែលបានជាប់នៅដំណាក់កាលទី១ នឹងត្រូវបានអញ្ជើញឲ្យចូលរួម សិក្ខាសាលាស្តីពីការសរសេរសំណើគម្រោង ដែលជាឱកាសពង្រឹងដល់ការរៀបចំសំណើគម្រោងរបស់ពួកគេ ដោយមានការសហការគ្នាជាក្រុមនឹងដៃគូផ្សេងទៀត ដោយមានការណែនាំពីលេខាធិការដ្ឋាន CEPF និងបុគ្គលិកអង្គការ IUCN។

**អ្នកដាក់សំណើគម្រោងទាំងអស់ ត្រូវដាក់សំណើរបស់ខ្លួនឲ្យបានត្រឹមម៉ោង ១១:៥៩យប់ (ម៉ោង នៅតំបន់ឥណ្ឌូចិន) នាថ្ងៃទី២៦ កញ្ញា ឆ្នាំ២០២២**។ រាល់សំណើទាំងឡាយណាដែលទទួលបានក្រោយវេលាម៉ោងនេះនឹងត្រូវបដិសេធ។ អ្នក នឹងទទួលបានអ៊ីម៉ែល ដោយបញ្ជាក់ពីការទទួលបានសំណើគម្រោងរបស់អ្នក។

លោកអ្នកអាចមើលចម្លើយចំពោះសំណួរដែលតែងតែសួរជារឿយៗ ត្រង់នេះ។ នៅចន្លោះថ្ងៃទី ២២

ដល់ ២៦ សីហា ឆ្នាំ២០២២។ អង្គការ IUCN នឹងរៀបចំវគ្គផ្តល់ព័ត៌មានតាមអនឡាញស្តីពីសេចក្តីប្រកាសទទួលយកសំណើសុំមូលនិធិ។ ព័ត៌មានលម្អិតនឹងមានផ្សព្វផ្សាយនៅលើបណ្តាញសង្គម IUCN Asia Facebook និង Twitter។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

ក្រុមការងារគ្រប់គ្រងមូលនិធិថ្នាក់តំបន់នៃមូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគម្រាមកំហែង

ការិយាល័យអង្គការ IUCN ប្រចាំតំបន់អាស៊ី

#៦៣ តំបន់សុខុមវិត ៣៩ វឌ្ឍថានា បាងកក ១០១១០ ថៃឡង់ដ៍

អ៊ីម៉ែល៖ CEPF-Indoburma@iucn.org

ទូរស័ព្ទ៖ +៦៦ ២ ៦៦២ ៤០២៩ ទូរសារ៖ +៦៦ ២ ៦៦២ ៤៣៨៩

## Table 27. Priority Corridors and Sites for Investment in the Indo-Burma Hotspot

| Priority Corridor | Priority Sites | Countries | Area (km$^2$) |
|---|---|---|---|
| | | | |
| Chindwin River | Upper Chindwin River: Kaunghein to Padumone Section | Myanmar | 5,281 |
| Mekong River and Major Tributaries | Lower Nam Ou; Mekong Confluence with Nam Kading; Mekong Confluence with Xe Bangfai; Mekong Channel near Pakchom; Mekong River from Kratie to Lao PDR; Mekong River from Phou Xiang Thong to Siphandon; Mekong River from Louangphabang to Vientiane; Pakxan Wetlands; Sekong River; Sesan River; Siphandon; Srepok River; Thala Stueng Treng; Ubon Nam Mun; Upper Lao Mekong; Upper Xe Kaman; Western Siem Pang; Xe Champhon | Cambodia, Lao PDR and Thailand | 19,435 |
| Myanmar Limestone Karst* | Ataran Taung Karst; Bayin Nyi Karst; Dhammata Karst; Himeinkanein Karst; Hpa-an; Hpruso Karst; Kayin Linno Karst; Kayon Karst; Kyauk Nagar; Montawa Cave; Myaleik Taung; Naung Ka Myaing Karst; Padamyar Karst; Panlaung-Pyadalin Cave; Parpant Caves; Pathein Karst; Pharbaung Karst; Phayartan Karst**; Sabel Karst; Tar Tar Karst; Waiponla Karst; Weibyan Karst; Yathae Pyan Karst; Ywangan Karst | Myanmar | 536 |
| Northern Plains Seasonally Inundated Forests | Chhep; Dong Khanthung; O Skach; Upper Stung Sen Catchment | Cambodia and Lao PDR | 19,322 |
| Sino-Vietnamese Limestone | Ba Be; Ban Bung; Ban Thi-Xuan Lac; Bangliang; Bat Dai Son; Binh An; Cham Chu; Chongzuo; Daweishan; Diding; Du Gia; Funing Niaowangshan; Fuping-Gula-Dingye; Gulongshan; Khau Ca; Lam Binh; Longhua; Longhushan; Longshan Section of Nonggang; Malipo; Na Chi; Nonggang; Paiyangshan; Shangsi-Biannian; Sinh Long; Tat Ke; Tay Con Linh; Than Xa; Trung Khanh; Tung Vai; Xidamingshan | China and Vietnam | 58,502 |
| Tonle Sap Lake and Inundation Zone | Ang Trapeang Thmor; Bakan; Boeung Chhmar-Moat Khla; Chhnuk Tru; Dei Roneat; Kampong Laeng; Lower Stung Sen; Preah Net Preah-Kra Lanh-Pourk; Prek Toal; Stung-Chi Kreng-Kampong Svay; Stung Sen-Santuk-Baray; Veal Srongae | Cambodia | 17,547 |

Notes: * = Myanmar Limestone Karst is a dispersed network of small sites, which does not meet the criteria for a conservation corridor but is nevertheless recognized as a geographic priority for CEPF investment under Strategic Directions 4 and 6. ** = Phayartan Karst is located within Lenya KBA but is several orders of magnitude smaller; therefore, only the limestone karst is considered a priority site and not the wider KBA within which it lies.